ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អន្តរក្រសួង

ក្រសួងមហាផ្ទៃ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា

ក្រសួងសុខាភិបាល

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
លេខ 2583
ថ្ងៃទី 01 ខែ 12 ឆ្នាំ 2010

ថ្ងៃទី 01 ខែ 12 ឆ្នាំ ១០
លេខ 1587

# សារាចរណែនាំអន្តរក្រសួង

## ស្តីពី

## របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

នាយកដ្ឋានរបបនអតីតយុទ្ធជន
លេខៈ ១៤៤
ថ្ងៃទី ០១ ខែ ១២ ឆ្នាំ ១០

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីរបបឧបត្ថម្ភគោលនយោបាយ ចំពោះ មន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ អន្តរក្រសួងរួមមាន ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលសូមធ្វើការណែនាំអនុវត្តដូចខាងក្រោម :

## I អំពីរចនាសម្ព័ន្ធ និងការកំណត់ភារកិច្ច សិទ្ធិរបស់ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ :

### ១. រចនាសម្ព័ន្ធ

ត្រូវបានបង្កើតក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ ដើម្បីពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការជូនមន្ត្រីនគរបាលជាតិដែលមានជំងឺ របួស ពិការឱ្យបានត្រឹមត្រូវតាមកម្រិតប្រភេទថ្នាក់ពិការដែលក្រសួងសុខាភិបាលបានកំណត់ ។

ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការត្រូវបានបង្កើតឡើងរួមមាន ២ថ្នាក់ ដូចខាងក្រោម :

- ថ្នាក់ជាតិ ។
- ថ្នាក់រាជធានី - ខេត្ត ។

នាយកដ្ឋានរបបនិវត្តន៍
ចូល
លេខ : ១៣៥០
ថ្ងៃទី : ០១ ១២ ២០១០

## ២. សមាសភាព

### ក- នៅថ្នាក់ជាតិ

រួមមានសមាសភាពចំនួន ៧រូប ដូចខាងក្រោម :

១. ប្រធាននាយកដ្ឋានសុខាភិបាលនៃក្រសួងមហាផ្ទៃ ជាប្រធាន

២. តំណាងក្រសួងសុខាភិបាល(ជាវេជ្ជបណ្ឌិត)០១រូប ជាអនុប្រធាន

៣. តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា០១រូប ជាអនុប្រធាន

៤. អនុប្រធាននាយកដ្ឋានបុគ្គលិកទទួលបន្ទុកការងារគោលនយោបាយនៃក្រសួងមហាផ្ទៃ០១រូប ជាសមាជិក

៥. វេជ្ជបណ្ឌិតផ្នែកវះកាត់របស់មន្ទីរពេទ្យនៃនាយកដ្ឋានសុខាភិបាលក្រសួងមហាផ្ទៃ០១រូប ជាសមាជិក

៦. វេជ្ជបណ្ឌិតផ្នែកជំងឺទូទៅរបស់មន្ទីរពេទ្យនៃនាយកដ្ឋានសុខាភិបាលក្រសួងមហាផ្ទៃ០១រូប ជាសមាជិក

៧. មន្ត្រីនគរបាលជាតិរបស់មន្ទីរពេទ្យនៃនាយកដ្ឋានសុខាភិបាលក្រសួងមហាផ្ទៃ០១រូប ជាលេខាធិការ ។

### ខ- នៅថ្នាក់រាជធានី-ខេត្ត

រួមមានសមាសភាពចំនួន ០៨ រូប ដូចខាងក្រោម :

១. ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ជាប្រធាន

២. តំណាងមន្ទីរសុខាភិបាលរាជធានី-ខេត្ត០១រូប ជាអនុប្រធាន

៣. តំណាងមន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទារាជធានី-ខេត្ត០១រូប ជាអនុប្រធាន

៤. នាយការិយាល័យបុគ្គលិករបស់ស្នងការដ្ឋាននគរបាលរាជធានី - ខេត្ត ០១រូប ជាសមាជិក

៥. វេជ្ជបណ្ឌិតផ្នែកវះកាត់របស់មន្ទីរពេទ្យរាជធានី-ខេត្ត០១រូប ជាសមាជិក

៦. វេជ្ជបណ្ឌិតផ្នែកជំងឺទូទៅរបស់មន្ទីរពេទ្យរាជធានី-ខេត្ត០១រូប ជាសមាជិក

៧. នាយ ឬនាយរងការិយាល័យសុខាភិបាលរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ០១រូប ជាសមាជិក

៨. នាយរងការិយាល័យបុគ្គលិកទទួលការងារគោលនយោបាយរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ០១ រូប ជាលេខាធិការ ។

## ៣. សមត្ថកិច្ចនៃការរៀបចំតែងតាំងសមាសភាពក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ :

ការតែងតាំងសមាសភាពក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការនៅថ្នាក់ជាតិនិងនៅថ្នាក់រាជធានី-ខេត្តនីមួយៗកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាត្រូវផ្តល់ឈ្មោះតំណាងរបស់ខ្លួនសម្រាប់ក្រុមប្រឹក្សាវាយ តម្លៃប្រភេទថ្នាក់ពិការនៅថ្នាក់ជាតិជូនក្រសួងមហាផ្ទៃ ។ ដោយឡែកក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការនៅថ្នាក់រាជធានី-ខេត្ត គឺមន្ទីរ

សុខាភិបាលនិងមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្តនីមួយៗត្រូវផ្ដល់ឈ្មោះតំណាងរបស់ខ្លួនជូនស្នងការដ្ឋាននគរបាលរាជធានី-ខេត្តដើម្បីបញ្ជូនមកក្រសួងមហាផ្ទៃ ។

## ៤. ភារកិច្ច និងសិទ្ធិ :

### ក. ភារកិច្ច :

- ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការរបស់ថ្នាក់ជាតិមានភារកិច្ចពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការជូនដល់មន្ត្រីនគរបាលជាតិដែលមានជំងឺរបួសពិការនៅតាមនាយកដ្ឋាន-អង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ

- ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការរបស់ថ្នាក់រាជធានី-ខេត្ត មានភារកិច្ចពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការជូនដល់មន្ត្រីនគរបាលជាតិដែលមានជំងឺ របួស ពិការនៅតាមស្នងការដ្ឋាននគរបាលរាជធានី - ខេត្ត ។

### ខ. សិទ្ធិ :

ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការគ្រប់ថ្នាក់មានសិទ្ធិ :

- ចេញវិញ្ញាបនបត្របញ្ជាក់ប្រភេទថ្នាក់ពិការជូនមន្ត្រីនគរបាលជាតិដែលមានជំងឺ របួស ពិការដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ។
- លើកជាសំណូមពរជូនដល់ប្រធានអង្គភាពឱ្យរៀបចំការងារឱ្យបានសមស្របទៅតាមលទ្ធភាពនិងសុខភាពរបស់មន្ត្រីនគរបាលជាតិដែលមានជំងឺ របួស ពិការ ក្នុងករណីដែលនៅបន្តការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

## ៥. របៀបរបបធ្វើការងារ :

ក-ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការគ្រប់ថ្នាក់ត្រូវធ្វើការពិនិត្យវាយតម្លៃប្រភេទ ថ្នាក់ពិការក្រោយពេលដែលមន្ត្រីនគរបាលជាតិទាំងនោះបានព្យាបាលជំងឺ របួសជាសះស្បើយ ។ សាមីខ្លួនត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- លិខិតស្នើសុំចេញវិញ្ញាបនបត្របញ្ជាក់ប្រភេទថ្នាក់ពិការរបស់សាមីខ្លួន ឬគ្រួសារ ឬអាណាព្យាបាល
- លិខិតទទួលស្គាល់របួស ពិការចេញដោយប្រធានអង្គភាពសាមី
- លិខិតអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យ
- លិខិតបញ្ជាក់លទ្ធផលនៃការព្យាបាល ។

ខ-ក្នុងករណីមន្ត្រីនគរបាលជាតិដែលមានជំងឺ របួស ពិការស្នើសុំពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការ ...

ឡើងវិញដោយសាររងរបួសបន្ថែម ទៀត ឬដោយសារជំងឺ របួសចាស់សើរើ ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការនៃសាមីជននោះត្រូវ ពិនិត្យ វាយតម្លៃ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភេទថ្នាក់ពិការឡើងវិញឱ្យបានច្បាស់លាស់ ។

បើមានការប្តឹងជំទាស់តវ៉ាអំពីករណីចំណាត់កម្រិតប្រភេទថ្នាក់ពិការ ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការនៃសាមីជននោះ ត្រូវរៀបចំសំណុំលិខិតឯកសារពាក់ព័ន្ធ និងវិញ្ញាបនបត្របញ្ជាក់ប្រភេទថ្នាក់ពិការបញ្ជូនមកក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការថ្នាក់ជាតិ ដើម្បីពិនិត្យ និងសម្រេច ។

គ-ការប្រជុំពិនិត្យវាយតម្លៃ កំណត់សម្រេចប្រភេទថ្នាក់ពិការអាចដំណើរការទៅបានលុះត្រាតែមានសមាសភាពរបស់ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការបានចូលរួមពី ២ ភាគ ៣ ឡើងទៅ ។

## II <u>ការផ្ទេរប្រគល់សំណុំលិខិតមន្ត្រីនគរបាលពលី មរណៈ និងពិការពីក្រសួងមហាផ្ទៃទៅ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា</u> :

### ១. <u>ការកំណត់បំពេញសំណុំលិខិត</u> :

*ក. ចំពោះមន្ត្រីនគរបាលពិការត្រូវមានសំណុំលិខិតដូចខាងក្រោម :*

- លិខិតផ្ទេរមន្ត្រីនគរបាលពិការពីក្រសួងមហាផ្ទៃជូនក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ចំនួន ០២ ច្បាប់ចេញដោយក្រសួងមហាផ្ទៃ
- ប្រកាសទទួលស្គាល់មន្ត្រីនគរបាលពិការចំនួន ០២ច្បាប់ ចេញដោយក្រសួងមហាផ្ទៃ
- បញ្ជីរាយនាមមន្ត្រីនគរបាលពិការចំនួន០២ច្បាប់ចេញដោយនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ
- លិខិតបញ្ជាក់ទទួលស្គាល់មន្ត្រីនគរបាលពិការចំនួន ០២ ច្បាប់ចេញដោយប្រធានអង្គភាពសាមី និងមានបញ្ជាក់ពីនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ
- វិញ្ញាបនបត្របញ្ជាក់ប្រភេទថ្នាក់ពិការ ( មានបិទរូបថតឯកសណ្ឋាននគរបាលជាតិទំហំ ៤ × ៦) ចំនួន ០២ ច្បាប់ចេញដោយក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ
- លិខិតឧទ្ទេសនាមផ្តល់ផ្តង់ហិរញ្ញវត្ថុចំនួន ០២ ច្បាប់ ចេញដោយប្រធានអង្គភាពសាមី និងមានបញ្ជាក់ពីនាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ
- ជីវប្រវត្តិសង្ខេបរបស់មន្ត្រីនគរបាលពិការចំនួន ០២ច្បាប់ និងមានបញ្ជាក់ពីប្រធានអង្គភាពសាមី
- លិខិតចម្លងប្រកាសទទួលស្គាល់មន្ត្រីនគរបាលពិការតាមរាជធានី-ខេត្ត ចំនួន ០២ច្បាប់

- រូបថតឯកសណ្ឋាននគរបាលជាតិទំហំ ៣ × ៤ ចំនួន ០៤ សន្លឹក ។

***ខ. ចំពោះមន្ត្រីនគរបាលពលី មរណៈ ត្រូវបំពេញសំណុំលិខិតដូចខាងក្រោម :***

- លិខិតផ្ទេរមន្ត្រីនគរបាលពលី មរណៈពីក្រសួងមហាផ្ទៃ ជូនក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាចំនួន ០២ច្បាប់ ចេញដោយក្រសួងមហាផ្ទៃ
- ប្រកាសទទួលស្គាល់មន្ត្រីនគរបាលពលី មរណៈ ចំនួន ០២ច្បាប់ ចេញដោយក្រសួងមហាផ្ទៃ
- បញ្ជីរាយនាមមន្ត្រីនគរបាលពលី មរណៈ ចំនួន ០២ច្បាប់ចេញដោយនាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ
- លិខិតបញ្ជាក់ទទួលស្គាល់មន្ត្រីនគរបាលពលី មរណៈចំនួន ០២ ច្បាប់ចេញដោយប្រធានអង្គភាពសាមីនិងមានបញ្ជាក់ពីនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ
- លិខិតឧទ្ទេសនាមផ្តត់ផ្គង់ហិរញ្ញវត្ថុចំនួន ០២ ច្បាប់ចេញដោយប្រធានអង្គភាពសាមី និងមានបញ្ជាក់ពីនាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ
- សេចក្តីចម្លងជីវប្រវត្តិសង្ខេបរបស់មន្ត្រីនគរបាលពលី មរណៈចំនួន ០២ ច្បាប់ចេញដោយប្រធានអង្គភាពសាមី
- លិខិតចម្លងប្រកាសទទួលស្គាល់មន្ត្រីនគរបាលពលី មរណៈតាមរាជធានី-ខេត្ត ចំនួន ០២ច្បាប់ ។

## ២. __នីតិវិធីនៃការផ្ទេរប្រគល់__ :

- ការផ្ទេរប្រគល់សំណុំលិខិតមន្ត្រីនគរបាលពលី មរណៈ និងពិការត្រូវធ្វើឡើងតាមលក្ខណៈការងាររដ្ឋបាលរវាងក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា
- នាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងនាយកដ្ឋានសោធនអតីតយុទ្ធជននៃក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ត្រូវធ្វើការត្រួតពិនិត្យរួមគ្នាជាមុននូវរាល់ឯកសារសំណុំលិខិតជនពលី ជនមរណៈ ជនពិការ ជាអតីតមន្ត្រីនគរបាលជាតិឱ្យបានត្រឹមត្រូវជាមុន ទើបធ្វើការប្រគល់ និងទទួលជាក្រោយ
- ក្រសួងមហាផ្ទៃក្រោយពេលចេញប្រកាសទទួលស្គាល់ជានគរបាលពលី មរណៈ បង្គស្លាប់ និងពិការត្រូវបន្តបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗរយៈពេល ៣ ខែជូនដល់គ្រួសារនគរបាលពលី មរណៈ បង្គស្លាប់និងមន្ត្រីនគរបាលពិការ ក្នុងចន្លោះពេលរង់ចាំទទួលប្រាក់ឧបត្ថម្ភគោលនយោបាយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាត្រូវចេញប្រកាសផ្តល់របបឧបត្ថម្ភជូនគ្រួសារជនពលី គ្រួសារជនមរណៈជនពិការជាអតីតមន្ត្រីនគរបាល ជាតិយ៉ាងយឺតបំផុតរយៈពេល ៩០ ថ្ងៃ ក្រោយពីបានទទួល ឯកសារនិងសំណុំលិខិតពីក្រសួងមហាផ្ទៃ ។

## III ការផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយជូនគ្រួសារមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួននិងមន្ត្រីនគរបាលពិការ :

### ១. ការទទួលខុសត្រូវផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ :

រៀងរាល់ឆ្នាំក្រសួងមហាផ្ទៃនិងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ត្រូវធ្វើគម្រោងផែនការចំណាយប្រាក់ឧបត្ថម្ភគោលនយោបាយ ជូនដល់មន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា។ ការទទួលបន្ទុកដោះស្រាយប្រាក់ឧបត្ថម្ភគោលនយោបាយត្រូវបានកំណត់ដូចខាងក្រោម :

***ក-ក្រសួងមហាផ្ទៃ :***

- ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់បូជា ឬបញ្ចុះសព
- ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសពមន្ត្រីនគរបាលពលី មរណៈ និងបង្កស្លាប់
- បន្តផ្តល់ប្រាក់បៀវត្សរ៍សរុបប្រចាំខែរបស់មន្ត្រីនគរបាលបាត់ខ្លួន ជូនគ្រួសារចាប់ពីថ្ងៃខែឆ្នាំបាត់ខ្លួនរហូតដល់គម្រប់១២ខែ ។ ក្រោយ ១២ខែនៅតែពុំឃើញត្រឡប់មកវិញ គ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើកដំបូងដូចគ្រួសារមន្ត្រីនគរបាលពលីដែរ
- ផ្តល់ប្រាក់បំប៉នសុខភាពនិងប្រាក់ជំនួយមុខរបួសជូនមន្ត្រីនគរបាលពិការដែលរស់នៅក្នុងមជ្ឈមណ្ឌលបំប៉នសុខភាព
- ផ្តល់ប្រាក់ជំនួយមុខរបួសជូនមន្ត្រីនគរបាលពិការដែលនៅបន្តការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- ផ្តល់ប្រាក់ឧបត្ថម្ភអតីតភាពការងារជូនមន្ត្រីនគរបាលពិការ ។

***ខ-ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា :***

- ផ្តល់ប្រាក់ឧបត្ថម្ភមួយលើកដំបូង និងបន្តបើកប្រាក់បៀវត្សរ៍សរុបប្រចាំខែជូនដល់នគរបាលពិការ
- ផ្តល់ប្រាក់ឧបត្ថម្ភជំនួយគ្រួសារប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់នគរបាលពលី មរណៈ

- ក្នុងករណីរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗដល់មន្ត្រីរាជការក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាត្រូវរៀបចំតម្លើងប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភជូនដល់ជនពិការ
- ចំពោះជនពិការប្រភេទ " ក "គ្រប់ថ្នាក់ជាអតីតមន្ត្រីនគរបាលជាតិ នៅពេលមរណភាពមានលិខិតមរណភាពរបស់មន្ត្រីអគ្រានុកូលដ្ឋានត្រូវទទួលស្គាល់ជាជនពលី និងត្រូវដោះស្រាយប្រាក់បូជា ឬ បញ្ចុះសពចំនួន០៩ខែនៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែរបស់អតីតសាមីជនពិការ។ ចំពោះគ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភ១លើកដំបូងចំនួន ១៥ ខែនិងត្រូវប្តូររបបមកជារបបឧបត្ថម្ភគ្រួសារជនពលីវិញតាមគោលការណ៍កំណត់។
- ចំពោះជនពិការប្រភេទ " ខ" គ្រប់ថ្នាក់ជាអតីតមន្ត្រីនគរបាលជាតិ នៅពេលមរណភាពមានលិខិតមរណភាពរបស់មន្ត្រីអគ្រានុកូលដ្ឋានត្រូវទទួលស្គាល់ជាជនមរណៈ និងត្រូវដោះស្រាយប្រាក់បូជាឬបញ្ចុះសពចំនួន០៧ខែ នៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែរបស់អតីតសាមីជនពិការ។ ចំពោះគ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភ១លើកដំបូងចំនួន ១២ ខែនិងត្រូវប្តូររបបមកជារបបឧបត្ថម្ភគ្រួសារជនមរណៈវិញតាមគោលការណ៍កំណត់។
- ចំពោះប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែ ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ត្រូវធ្វើផែនការចំណាយជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ២០ នៃខែមុនដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផ្តល់ថវិកាបានទាន់ពេលវេលា ។

*គ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :*

ក្រោយពេលដែលក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាធ្វើអាណត្តិសុំផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយដែលមានភ្ជាប់នូវសំណុំលិខិតយុត្តិការគ្រប់គ្រាន់ ត្រឹមត្រូវហើយនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការទៅតាមលទ្ធភាពនៃឥណទានថវិកានិងឥណទានដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗឱ្យបានទាន់ពេលវេលាដើម្បីក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាអនុវត្តការបើកប្រាក់ឧបត្ថម្ភគោលនយោបាយឱ្យបានទាន់ពេលវេលា ។

## ២. នីតិវិធីនៃការបើកប្រាក់ឧបត្ថម្ភគោលនយោបាយ :

- នគរបាលពិការដែលមកបើកប្រាក់ឧបត្ថម្ភគោលនយោបាយនៅក្រសួងមហាផ្ទៃត្រូវមានឈ្មោះក្នុងប្រកាសទទួលស្គាល់ជាមន្ត្រីនគរបាលពិការ។ ដោយឡែកចំពោះគ្រួសារនគរបាលពលី មរណៈនិងបង្កស្លាប់ដែលមកបើកប្រាក់ឧបត្ថម្ភគោលនយោបាយត្រូវមានឈ្មោះក្នុងសេចក្តីចម្លងជីវប្រវត្តិសង្ខេបរបស់មន្ត្រី នគរបាល ពលី មរណៈ និងបង្កស្លាប់

- គ្រួសារនគរបាលពលី មរណៈនិងនគរបាលពិការដែលត្រូវមកបើកប្រាក់ឧបត្ថម្ភនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាត្រូវមានឈ្មោះក្នុងប្រកាសទទួលស្គាល់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- គ្រួសារនគរបាលពលី មរណៈ និងនគរបាលពិការនៅពេលមានធុរៈធ្ងន់ធ្ងរមិនអាចមកបើកបាន ត្រូវធ្វើលិខិតផ្ទេរសិទ្ធិឱ្យអ្នកមកបើកជំនួសដោយមានការបញ្ជាក់ទទួលស្គាល់ពីអង្គភាពគ្រប់គ្រង ឬ អាជ្ញាធរមូលដ្ឋានរបស់សាមីខ្លួន និងភ្ជាប់មកជាមួយនូវសំណុំលិខិតពាក់ព័ន្ធ
- ការផ្តល់ប្រាក់ឧបត្ថម្ភជូនគ្រួសារជនពលី គ្រួសារជនមរណៈ និងជនពិការជាអតីតមន្ត្រីនគរបាលជាតិត្រូវបើកជូនដល់ដៃ និងគ្រប់ចំនួនតាមរបបកំណត់ដោយត្រូវមានផ្តិតមេដៃ ឬចុះហត្ថលេខាទទួលប្រាក់ពីសាមីជន ។

## IV វិធានការចាត់តាំងអនុវត្ត :

ដើម្បីអនុវត្តសារាចរណែនាំអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងសម្រេចបានលទ្ធផលល្អប្រសើរ គ្រប់អង្គភាពជំនាញដែលមានការពាក់ព័ន្ធ និងស្ថិតក្រោមឱវាទក្រសួងនីមួយៗត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោម :

- ការពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការជាភារកិច្ចមួយស្មុគស្មាញទាក់ទងទៅនឹងការងារបច្ចេកទេសវេជ្ជសាស្ត្រ ដូចនេះទាមទារការពិនិត្យត្រូវធ្វើឱ្យបានហ្មត់ចត់ និងមានភាពសុក្រិត ។
- ក្នុងកិច្ចដំណើរការអនុវត្ត និងដោះស្រាយរបបឧបត្ថម្ភជូនគ្រួសារជនពលី គ្រួសារជនមរណៈ និងជនពិការ ជាអតីតមន្ត្រីនគរបាលជាតិ ពេលជួបបញ្ហាលំបាកនាយកដ្ឋានជំនាញ ឬអង្គភាព របស់ក្រសួងនីមួយៗត្រូវជួបប្រជុំពិភាក្សាដោះស្រាយជាក់ស្តែងនិងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងរៀងៗខ្លួនបានជ្រាប។ ករណីមានការលំបាកស្មុគស្មាញធ្ងន់ធ្ងរមិនអាចដោះស្រាយបាន ថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធទាំងអស់ត្រូវជួបប្រជុំពិភាក្សាដោះស្រាយបន្ទាន់
- ត្រូវមានការប្រជុំដកពិសោធន៍ការងារជារួមរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ជាត្រីមាស ឆមាស ឬប្រចាំឆ្នាំដើម្បីលើកឡើងនូវទិសដៅឱ្យបានសមស្របតាមសភាពការណ៍រីកចម្រើនរបស់ប្រទេសជាតិ

- នាយកដ្ឋានជំនាញនិងអង្គភាពពាក់ព័ន្ធរបស់ក្រសួងនីមួយៗមានភារកិច្ចអនុវត្តសារាចរណែនាំអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសារាចរណែនាំអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

សារាចរណែនាំអន្តរក្រសួងនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច**
**អតីតយុទ្ធជន និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

កន្លែងទទួល:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់នាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ចំណុះឱ្យក្រសួងទាំងបួន
- ឯកសារ-កាលប្បវត្តិ